ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ០៧៤ ប្រក កសក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់គំរូសៀវភៅនាវាចរនេសាទ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស្រ្តសាស្ត្រ និងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល

## ស ម្រេ ច

**ប្រការ ១** : ដាក់ឱ្យប្រើប្រាស់គំរូសៀវភៅនាវាចរនេសាទក្នុងគោលបំណងដើម្បីគ្រប់គ្រង និងតាមដានសកម្មភាពនាវាចរនេសាទដែលធ្វើអាជីវកម្មនេសាទគ្រប់ប្រភេទ។ សៀវភៅនាវាចរនេសាទមានភ្ជាប់ជាមួយក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២** : នាវានេសាទគ្រប់ប្រភេទមានចំណុះផ្ទុកលើសពី ៥០០ គ.ក្រ ដែលធ្វើអាជីវកម្មនេសាទ ត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងសៀវភៅនាវាចរនេសាទ ដើម្បីធានាសុវត្ថិភាពសណ្តាប់ធ្នាប់ចរាចរ និងអាយុជីវិតអ្នកនេសាទ។

អាស័យដ្ឋានលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº.200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D. Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១/២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 – 217 320

**ប្រការ៣** : គំរូសៀវភៅនាវានេសាទមានក្របពណ៌ខៀវខ្ចី និងស្លាកសញ្ញាជលផលកម្ពុជា មានអង្កត់ផ្ចិតប្រវែង ១១០ មម ។ សៀវភៅនាវានេសាទ ត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃពីរដ្ឋបាលជលផល ។

**ប្រការ ៤** : អ្នកបើកបរនាវានេសាទ ត្រូវរក្សាទុកសៀវភៅនាវានេសាទឱ្យបានគង់វង្ស មិនរហែក ឬបាត់បង់សន្លឹកឡើយ ហើយត្រូវបង្ហាញដល់ភ្នាក់ងារជលផលមានសមត្ថកិច្ចនៅរាល់ពេលត្រួតពិនិត្យ ។ ក្នុងករណីបាត់បង់ អ្នកបើកបរនាវានេសាទត្រូវរាយការណ៍ជាបន្ទាន់ជូនសមត្ថកិច្ចជលផល ដើម្បីស្នើសុំសៀវភៅនាវានេសាទជាថ្មី ។

**ប្រការ ៥** : ជនណាដែលក្លែងបន្លំសៀវភៅនាវានេសាទ ឬប្រព្រឹត្តផ្ទុយនឹងខ្លឹមសារដែលមានចែងក្នុងប្រកាសនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៦** : ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧** : អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធានរដ្ឋបាលជលផល ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១០

**រដ្ឋមន្ត្រី**

**ចាន់-សារុន**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- សាលារាជធានី-ខេត្តពាក់ព័ន្ធ
- ដូចប្រការ ៧ " <u>ដើម្បីអនុវត្ត</u> "
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ.. ........ .......ចុះថ្ងៃទី...........ខែ.................ឆ្នាំ ២០១០

ស្តីពីការដាក់ឱ្យប្រើប្រាស់គំរូសៀវភៅនាវានេសាទ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## រដ្ឋបាលជលផល

# សៀវភៅនាវានេសាទ

លេខនាវានេសាទ :.........................................

## លក្ខណៈសម្គាល់នាវានេសាទ

១-ឈ្មោះនាវា : ............................................................ លេខប័ណ្ណសម្គាល់នាវា : .....................................

ទីកន្លែងចុះបញ្ជី : ........................................................................ ឆ្នាំចុះបញ្ជី : ....................................

២-ឈ្មោះម្ចាស់កម្មសិទ្ធិ : ..............................ភេទ .............. អាយុ............ឆ្នាំ សញ្ជាតិ...........................

អត្តសញ្ញាណប័ណ្ណលេខ....................................................

៣-អាសយដ្ឋានបច្ចុប្បន្ន : ..........................................................................................................

៤-លេខរៀងសម្គាល់នាវានេសាទ : ................... ទីកន្លែងចុះបញ្ជី ............................. ឆ្នាំចុះបញ្ជី ...............

៥- កាលបរិច្ឆេទស្ថាបនា : ........................... ទីកន្លែងស្ថាបនា ....................................................................

៦-ប្រភេទសំបក : ................................................... ពណ៌ ....................................................................

៧-ទំហំ : បណ្ដោយ ............................. ទទឹង ............................ ជម្រៅ .........................................

៨-ចំណុះផ្ទុក : .......................................តោន ចំនួនឃ្លុប .......................................................................

៩-ប្រភេទម៉ាស៊ីន : ...............................កំលាំងម៉ាស៊ីន. .................... សេះ លេខម៉ាស៊ីន ............................

បែប...................................................... ចំនួនម៉ាស៊ីន .................... គ្រឿង

១០-ទីតាំងដាក់ម៉ាស៊ីន : ...................................................... ប្រភេទប្រអប់លេខ .................................

១១-គុណភាពនាវានេសាទ :.........................................................................................................

១២-ប្រភេទឧបករណ៍នេសាទ :................................ ទំហំ............................................ ចំនួន...............

១៣-គុណភាពឧបករណ៍នេសាទ : ..........................................................................................................

១៤-កំលាំងពលកម្មសរុប : ................................ នាក់។

ធ្វើនៅ........................ ថ្ងៃទី............ខែ.................ឆ្នាំ ២០.......

**នាយអធិការដ្ឋានរដ្ឋបាលជលផល**...............................

# តារាងត្រួតពិនិត្យបច្ចេកទេសនាវានេសាទ

| លក្ខណៈបច្ចេកទេស | ការវាយតម្លៃរបស់សមត្ថកិច្ចត្រួតពិនិត្យ | ថ្ងៃណាត់ជួប |
|---|---|---|
| ១- ទង់ជាតិ | | |
| ២- ប្រព័ន្ធម៉ាស៊ីន | | |
| ៣- ប្រព័ន្ធចង្កូត | | |
| ៤- ប្រព័ន្ធប្រអប់លេខ | | |
| ៥- ប្រព័ន្ធស្រាវខ្សែ ( ត្រើយ ) | | |
| ៦- ដងស្ទូច | | |
| ៧- ភ្លើងសញ្ញា | | |
| ៨- សញ្ញាចរាចរ | | |
| ៩- សំបកនាវា | | |
| ១០- ឧបករណ៍សុវត្ថិភាព | | |
| - ពោងសង្គ្រោះ-អាវសង្គ្រោះ | | |
| - ឧបករណ៍ពន្លត់អគ្គីភ័យ | | |
| - ម៉ាស៊ីនបូមទឹក | | |
| - សញ្ញាប្រកាសអាសន្ន | | |
| - យុថ្កា | | |
| - ឧបករណ៍មើលជម្រៅទឹក | | |
| - ឧបករណ៍នាំផ្លូវ | | |
| - កែវយឺត | | |
| - ឧបករណ៍សម្រាប់ជួសជុល | | |
| ១១- វិទ្យុទាក់ទង | | |
| ១២- ធុងសំរាម | | |
| ១៣- ប្រអប់ថ្នាំពេទ្យ | | |
| ១៤ - ធុង ឬ ឃ្លូបទឹកកក | | |
| ១៥- កន្លែងទុកឧបករណ៍នេសាទ | | |

ធ្វើនៅ........................ថ្ងៃទី............ខែ..................ឆ្នាំ ២០........

**នាយខណ្ឌរដ្ឋបាលជលផល**..........................

# បញ្ជីរាយនាមអ្នកបើកបរ និង កម្មករនេសាទ

| ល.រ | នាម-គោត្តនាម | ឋានៈ | សញ្ជាតិ | ថ្ងៃ.ខែ.ឆ្នាំកំណើត | លេខអត្តសញ្ញាណប័ណ្ណ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| ៧ | | | | | | |
| ៨ | | | | | | |
| ៩ | | | | | | |
| ១០ | | | | | | |
| ១១ | | | | | | |
| ១២ | | | | | | |
| ១៣ | | | | | | |
| ១៤ | | | | | | |
| ១៥ | | | | | | |
| ១៦ | | | | | | |
| ១៧ | | | | | | |
| ១៨ | | | | | | |
| ១៩ | | | | | | |
| ២០ | | | | | | |
| ២១ | | | | | | |
| ២២ | | | | | | |
| ២៣ | | | | | | |

សរុបត្រឹមចំនួន.................នាក់ ធ្វើនៅ......................ថ្ងៃទី.........ខែ.............ឆ្នាំ២០.....

**នាយផ្នែករដ្ឋបាលជលផល**......................

# សេចក្តីណែនាំ

១ - សៀវភៅនាវានេសាទ ត្រូវបានផ្តល់ដោយរដ្ឋបាលជលផល ។

២ - សៀវភៅនេះ ត្រូវរក្សាទុកឱ្យបានគង់វង្ស ដើម្បីបង្ហាញដល់សមត្ថកិច្ចត្រួតពិនិត្យ ។

៣ - ម្ចាស់នាវានេសាទ ត្រូវអនុវត្តតាមសេចក្តីណែនាំរបស់សមត្ថកិច្ចត្រួតពិនិត្យ ។

៤ - ក្នុងករណីបាត់បង់ ម្ចាស់សៀវភៅនាវានេសាទ ត្រូវធ្វើពាក្យបណ្តឹងជាបន្ទាន់មកខណ្ឌរដ្ឋបាលជលផល ដោយមានការបញ្ជាក់ពីអាជ្ញាធរដែនដី ដើម្បីស្នើសុំសៀវភៅថ្មី ។

៥ -អ្នកក្លែងសៀវភៅនាវានេសាទនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។